ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ១១ កើត ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ
## ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាង
## «យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»

នាព្រឹកថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ.), គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាង «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣**» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័ន, សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធ ។

សេចក្តីព្រាង «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣**» នេះ ត្រូវបានរៀបចំឡើងអនុលោមតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្តជាអន្តរជាតិ ដោយ÷ ១. ពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ ព្រមទាំង ២. វិភាគលើហានិភ័យ, បញ្ហាប្រឈម, និងកាលានុវត្តភាពនៃការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា ហើយនឹងដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រមួយចំនួន ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចដែលកាន់តែរីកលូតលាស់ និងមានភាពស្មុគស្មាញជាងមុន សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះ ក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ។ ជាមួយគ្នានេះ, ដើម្បីធានាបាននូវភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនានា, សេចក្តីព្រាង «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣**» នេះ ត្រូវបានដាក់ឆ្លងកិច្ចពិភាក្សាកម្រិតបច្ចេកទេសផ្ទៃក្នុង ក.ស.ហ.វ. ជាច្រើនលើកច្រើនសារ ដែលកិច្ចប្រជុំពិគ្រោះយោបល់ចុងក្រោយ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៩ ក្រោមការដឹកនាំរបស់ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ទង្សី វិសុទ្ធ** អនុប្រធានប្រចាំការ នៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មុននឹងយកមកដាក់ឆ្លងកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ នាពេលនេះ ។

ដើម្បីបន្តធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ក្នុងរយៈពេលមធ្យម និងវែង, សម្រាប់ឆ្នាំ ២០១៩-២០២៣, រាជរដ្ឋាភិបាលនឹងប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះ ទាំង ៥ រួមមាន÷

**១.** ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន;

**២.** ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់;

**៣.** ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម;

**៤.** ប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និង ស័ក្តិសិទ្ធិភាពខ្ពស់បំផុត; និង

**៥.** ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

អង្គប្រជុំ បានវាយតម្លៃខ្ពស់អំពីសារៈសំខាន់នៃ**«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»** នេះ ហើយបានពិភាក្សាស៊ីជម្រៅលើខ្លឹមសារតាមជំពូកនីមួយៗ នៃសេចក្តីព្រាងយុទ្ធសាស្ត្រ សំដៅធានាបាននូវសង្គតិភាព និងភាពប្រទ្បាក់ក្រឡាជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមតិយោបល់ល្អៗ របស់សមាជិក-សមាជិកានៃអង្គប្រជុំ ព្រមទាំងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារបច្ចេកទេស អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃ ក.ស.ហ.វ ដែលបានរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ៕